# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


១៧-០១-២០០៥ -ព្រះរាជក្រម នស/រកម/០១០៥/០០១ ច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១៨១

១៧-០១-២០០៥ -ព្រះរាជក្រម នស/រកម/០១០៥/០០២ ច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ១៨៣

១៧-០១-២០០៥ -ព្រះរាជក្រម នស/រកម/០១០៥/០០៣ ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១៨៥


### ២-ព្រះរាជក្រឹត្យ


១៧-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០១២ ស្តីពីការតម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ជូនឧត្តមសេនីយ៍ទោ **លុ រ៉ាមីន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ១៨៧

១៧-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០១៣ ស្តីពីការតម្លើងឋានន្តរស័ក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ១៨៨

១៩-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០១៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនលោក **តាំង ចិន** (TANG ZHEN) សញ្ជាតិដើមចិនកើតនៅខេត្ត សានទុង ប្រទេសចិន ១៨៩


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៧-០១-២០០៥ -អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្តីពីការផ្ទេរគេហទានថវិកា ១៩០

១៩-០១-២០០៥ -អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពីការទទួលស្គាល់ការប្រែក្លាយ **វិទ្យាស្ថាន អាស៊ី អឺរ៉ុប** ទៅជា **សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប** ១៩២

១៧-០១-២០០៥ -អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៥

១៧-០១-២០០៥ -អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៧

១៧-០១-២០០៥ -អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៨

| | | |
|---|---|---|
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៣៥អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ១៩៩ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៣៦អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ២០០ |
| ១៧-០១-២០០៥ | -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការ | ២០១ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ | ២០២ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០៣ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២០៤ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០៥ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ៤២អនក្រ.តត ស្តីពីការប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ | ២០៦ |
| ១៨-០១-២០០៥ | -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០៨ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្តីពីការកែសំរួលសមាសភាពក្រុមប្រឹក្សាកំណែទំរង់ កងយោធពលខេមរភូមិន្ទ | ២១០ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្តីពីការផ្លាស់ប្តូរសមាសភាពតំណាងក្រសួងពាណិជ្ជកម្ម នៅក្នុងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២១៤ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២១៦ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២១៧ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៨ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២០ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២២ |
| ១៩-០១-២០០៥ | -អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៣ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២២៤ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៦ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២២៧ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៨ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២៩ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៣០ |
| ២០-០១-២០០៥ | -អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៣១ |

២១-០១-២០០៥ -អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៣
២១-០១-២០០៥ -អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៤

## ២.សេចក្តីសំរេច

១៨-០១-២០០៥ -សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ២៣៥
១៩-០១-២០០៥ -សេចក្តីសំរេចលេខ ០៥ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីចរចាជាមួយភាគីចិនអំពីការទិញនាវាប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធតាមដង សមុទ្រ ២៣៩
១៩-០១-២០០៥ -សេចក្តីសំរេចលេខ ០៦ សសរ ស្តីពីការបង្កើតគណៈកម្មការឯកជនភាវូបនីយកម្មនៃរាជាយស្ម័យានកម្ពុជាលើការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ ២៤១

## III.ការងារបណ្តាក្រសួង

## ១.ឋិស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-០១-២០០៥ -ប្រកាសលេខ ០៣៣ សហវ.ប្រក ស្តីពីការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករចំពោះប្រាក់ពន្ធប្រាក់ពន្ធបន្ថែម និងការប្រាក់ដែលសហគ្រាសត្រូវបង់ ២៤៣
១៤-០១-២០០៥ -សេចក្តីជូនដំណឹងលេខ ០១៥ សហវ.សជណ ស្តីពីការប្រកាសឱ្យម្ចាស់យានយន្តគ្រប់ប្រភេទ ដែលខកខានក្នុងការបំពេញបែបបទបង់ពន្ធ និងអាករនាំចូលស្របច្បាប់ ឱ្យចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធឱ្យបានរួសរាន់ ២៤៦
១៩-០១-២០០៥ -សេចក្តីជូនដំណឹងលេខ ០១៧ សហវ.សជណ ស្តីពីការអញ្ជើញអ្នកដែលជំពាក់ពន្ធទាំងឡាយឱ្យមកធ្វើការទូទាត់បំណុលពន្ធ ២៤៧

## ២.ឋិស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-០១-២០០៥ -ប្រកាសលេខ ០៧០ MOC/M 2005 ស្តីពីការកែសំរួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ ប្រភពដើមទំនិញ , វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ ២៤៨

# ព្រះរាជក្រម

នស/រកម/០១០៥/០០១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៦៨/០១០/២០០៤ កបធ.ច ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ហើយ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើវិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ-នីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣/ល.០៥០១.០១៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាង តាន់

# ព្រះរាជក្រម

នស/រកម/០១០៥/០០២

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែតុលាឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្ដីសម្រេចលេខ ០៦៧/០០៩/២០០៤កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្ដីពី
# ការបង្កើតក្រសួងកិច្ចការនារី

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងកិច្ចការនារី ពីពេលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រសួងកិច្ចការនារី មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងកិច្ចការនារី ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលរងដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ចរស.០៥០១.០១៥* **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារី គាន់**

# ព្រះរាជក្រម

នស/រកម/០១០៥/០០៣

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៦៦/០០៨/២០០៤ កបធ.ធ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស.០៥០១.០០៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

នស/រកត/០១០៥/០១២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យ ប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឧត្តមសេនីយ៍ទោ លូ រីមិន អត្តលេខ ០០៥៣ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០១.០១២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥*

អនុ: ៦៥ ច.ល
**ដើម្បីចម្លងចេញ**
រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible] តាន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានន្តរស័ក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

ក- ថ្នាក់ឧត្តមសេនីយ៍ទោ :

- លោកឧត្តមសេនីយ៍ត្រី គីម ចាន់នី អត្តលេខ ០០៦៧ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី :

| | | | |
|---|---|---|---|
| ១- លោកវរសេនីយ៍ឯក | សេត តូមី | អត្តលេខ | ០២៩៨ |
| ២- លោកវរសេនីយ៍ឯក | គីម សារេន | អត្តលេខ | ០៣៥៨ |
| ៣- លោកវរសេនីយ៍ឯក | តែង ឥណ្ឌថន | អត្តលេខ | ០៣៦០ |
| ៤- លោកវរសេនីយ៍ឯក | មួង ឃឹម | អត្តលេខ | ០៣៩៨ |

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ៕

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

តាល.០៥០១.០១៣

លេខ: ៦០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សំរាជ ការដំ (signature)

សាន់ គាន់

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០១៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនលោក **តាំង ចិន** ( TANG ZHEN ) សញ្ជាតិដើមចិន កើតថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧៧ នៅខេត្ត សានទុង ប្រទេសចិន។

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ០៥០១. ០១៧

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥*

លេខ ០១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible]**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ***សំរេច***

***មាត្រា១:*** *ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៨០.៤០០.០០០ រៀល ( ប៉ែតសិបលានបួនរយពាន់រៀលគត់ ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការផ្គត់ផ្គង់ ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។*

***មាត្រា២:*** *ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ ។*

***មាត្រា៣:*** *រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។*

*រាជធានីភ្នំពេញ . ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *កាលប្បវត្តិ . ឯកសារ*

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...............

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់វិទ្យាស្ថាន អាស៊ី អឺរ៉ុប
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៩២ អយក.ឧស ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៥

[illegible]

មាត្រា ១ : ទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប "Asia Euro University" ហៅកាត់ជាភាសាខ្មែរ "ស.អ.អ." និងហៅកាត់ជាភាសាអង់គ្លេស "AEU" ។

សាកលវិទ្យាល័យនេះ មានទីតាំង ៤ កន្លែង នៅរាជធានីភ្នំពេញ :

. ទីតាំងទី ១ ជាទីតាំងគោលស្ថិតនៅអាគារលេខ ៨៣២ ABCD មហាវិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក

. ទីតាំងទី ២ ស្ថិតនៅអាគារលេខ ៦៩៣ មហាវិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក

. ទីតាំងទី ៣ ស្ថិតនៅអាគារលេខ ១៦២ ផ្លូវសហព័ន្ធរ៉ុស្ស៊ី សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន

. ទីតាំងទី ៤ ស្ថិតនៅអាគារលេខ ១៦១ ផ្លូវលេខ ១៦១ សង្កាត់វាលវង់ ២ ខណ្ឌ៧មករា ។

មាត្រា ២ : សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ធ្វើការបណ្តុះបណ្តាលកម្រិត :

- បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម
- បរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម
-ម៉ាស្ទ័រ សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម ។

សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិតដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានមហាវិទ្យាល័យចំនួន ០៥ និងថ្នាក់ក្រោយបរិញ្ញាបត្រ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យ សង្គមសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- ថ្នាក់ក្រោយបរិញ្ញាបត្រ ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យ ឯកទេស ឬប្រភេទអប់រំបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាលកវិទ្យាល័យនេះ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៧ : សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវគោរព អនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារ

[illegible] ។

មាត្រា ៨ : សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប មានភារកិច្ចទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ធានាឱ្យបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

មាត្រា ៩ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១០ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១១ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង ធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូន សប្បុរសជន ចំនួន ១៧រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងសមិទ្ធផល លើវិស័យព្រះពុទ្ធសាសនា នៅក្នុងវត្តលង្កា ព្រះកុសមារាម សង្កាត់បឹងកេងកង ទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក/មេដាយមាសស្ថាបនាជាតិ :**

១-សម្តេចព្រះពោធិវង្ស **ឧន្ទ ង៉ែត** សង្ឃនាយករងទី១ គណៈមហានិកាយ អធិការពុទ្ធិកសិក្សាទូទាំងប្រទេស និង ជាព្រះមេគណ ក្រុងភ្នំពេញ បច្ច័យ ចំនួន ១៤.០១២ ដុល្លារ

២-ព្រះញាណកោសល **សោរ៉ា ចំនួនផុល្ល** អធិការរងពុទ្ធិកសិក្សាទូទាំងប្រទេស អនុគណខណ្ឌចំការមន និង ជា ព្រះចៅអធិការវត្តលង្កាព្រះកុសមារាម បច្ច័យ ចំនួន ២៥.៦៦០ ដុល្លារ

៣-ឯកឧត្តម **ម៉ប់ សារិន** អភិបាលរង រាជធានីភ្នំពេញ ថវិកា ចំនួន ១៣.២១០ ដុល្លារ

**ខ/មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះមហា **សូរ សារិទ្ធិ** នាយកពុទ្ធិកវិទ្យាល័យ សម្តេចព្រះពោធិវង្ស **ឧន្ទ ង៉ែត** លង្កា និង ជា គ្រូសូធ្យឆ្វេង វត្តលង្កាព្រះកុសមារាម បច្ច័យ ចំនួន ៨.២៩៥ ដុល្លារ

២ ព្រះមហា **ទ៉ុង សុភក្តិ** ព្រះវិន័យធរ ខណ្ឌចំការមន បច្ច័យ ចំនួន ៨.១២០ ដុល្លារ

៣-លោក **ខៀវ ថន** ប្រធានកិត្តិយស វត្តលង្កាព្រះកុសមារាម ថវិកាចំនួន ៨.១០០ ដុល្លារ

៤-លោកស្រី **ឆ្នាក់ មាលី** ចៅសង្កាត់បឹងកេងកង ១ ថវិកា ចំនួន ៨.១៣០ ដុល្លារ

៥-លោកស្រី **ឥន្ទ សុផល្លា** សប្បុរសជន ថវិកា ចំនួន ៧.០១៦ ដុល្លារ

៦-លោកស្រី **ឡឹ សុខសាន** សប្បុរសជន ថវិកា ចំនួន ៨.០០០ ដុល្លារ

៧-លោក **ឈូរ ចាង** សប្បុរសជន ថវិកា ចំនួន ៧.០១០ ដុល្លារ

**គ/មេដាយសេរីវឌ្ឍស្ថាបនាជាតិ :**

១-ព្រះមហា **ផាន់ ចំនួនសារា** លេខាអនុគណ ខណ្ឌចំការមន បច្ច័យ ចំនួន ៤.២០០ ដុល្លារ

២-ព្រះមហា **ស៊ុម សាវ៉ន** លេខាសង្ឃ វត្តលង្កាព្រះកុសមារាម បច្ច័យ ចំនួន ៣.៩២០ ដុល្លារ

៣-ព្រះមហា **ធ្នាក់ ឡឹ** ប្រធានគណៈកម្មការវត្តលង្កាព្រះកុសមារាម បច្ច័យចំនួន ៣.២០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៣......អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីទទួលបន្ទុកមហាអនុតំបន់មេគង្គ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **តុំ សោ** ជាជំនួយការរបស់ឯកឧត្តម **យី តាំងលីម** ទេសរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីទទួល បន្ទុកមហាអនុតំបន់មេគង្គ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៣៤...អនក្រ - បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស៊ើង ហ៊ុនលី** ( Mr.SEUNG HOON LEE ) ជនជាតិកូរ៉េ ជានាយកក្រុមហ៊ុន GREEN POWER & SOLARESCO Co.LTD ប្រចាំនៅកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយតំលើងប្រព័ន្ធថាមពលព្រះអាទិត្យបំពាក់ដល់ ស្ពានព្រែកតាកៅ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្ពានសោប១ ស្ពានសោប២ និង ស្ពានព្រែកតាម៉ៅ នៅឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ អស់ទឹកប្រាក់សរុបចំនួន ១៥.៥០០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អភិបាលខេត្តកំពង់ចាម និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
B12 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-**

ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកវរសេនីយ៍ទោ **ស៊ុន សារិន្ទ** អត្តលេខ ០១៦៩៦

២- លោកវរសេនីយ៍ទោ **សម សណ្ឋិរៈ** អត្តលេខ ០២១៧៩

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យនុបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៦ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ .-**

ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ ពៅ ស៊ីដន អត្តលេខ ០៧៤៥ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៣៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង
- យោងអនុក្រឹត្យលេខ ៣៨៨.អនក្រ.តត ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល
- យោងលិខិតលេខ ០០២.មសត្រ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សំរេច

**មាត្រា ១ :** ត្រូវបានលុបឈ្មោះលោក **យឹម វិណារុធ** អត្តលេខ ១៦៥១៤០០០២៦ ជាមន្ត្រី ថ្នាក់លេខ ១០ អនុប្រធាននាយកដ្ឋានរដ្ឋបាល ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ចេញពីក្របខ័ណ្ឌក្រសួងព្រះបរមរាជវាំង ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ នេះតទៅ ។

**មាត្រា ២ :** ចំពោះប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងឧបត្ថម្ភផ្សេងៗ របស់លោក **យឹម វិណារុធ** ត្រូវលុបចេញពីតារាងទូទាត់ប្រាក់បៀវត្ស នៃក្រសួងព្រះបរមរាជវាំង នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ នេះដែរ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ត្រី **ចៅ ឫទ្ធិសក្តិ** អត្តលេខ ០០៤៧ បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋានកណ្តាលនគរបាលព្រំដែន មកជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

២- លោកឧត្តមសេនីយ៍ត្រី **សុខ សួស្តី** អត្តលេខ ០០៧៦ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន មកជាអនុប្រធានទី១នាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

៣- លោកឧត្តមសេនីយ៍ត្រី **ខន ឈុនលី** អត្តលេខ ០១០៧ ជាប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០...*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*- ដូចមាត្រា ២*
*- ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ០៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៖៙៖

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង សាលារៀន ផ្លូវថ្នល់ ស្ពានប្រឡាយ និង សមិទ្ធផលផ្សេងៗទៀត ស្ថិតនៅក្នុងឃុំបាស្រែ ឃុំពន្លៃ និង ឃុំព្រៃផ្គាំ ស្រុកអង្គរបូរី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឆាន់ ចាន់ធុល** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ២-លោក | **សម នៅ** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១៣.៣០០ ដុល្លារ |
| ៣-លោក | **ម៉ែន ឌុច** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ៤-លោក | **ពុំ សុផា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.៣០០ ដុល្លារ |
| ៥-លោក | **ណាប់ សុខហ៊ីម** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.១០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ស្រ៊ុន លីមហុង** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ២-លោក | **រស់ ឌុន្នី** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ៥.២០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៣-លោក **ចាប ច័ន្ទដារ៉ា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន | ៥.៣០០ ដុល្លារ |
| ៤-លោក **ឈុន ឃាំងតុង** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន | ៥.៣០០ ដុល្លារ |
| ៥-លោក **ឡេង សុវណ្ណ** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន | ៥.១០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.90.91

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ឡូន សុជល** ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រី ០២ រូប របស់ក្រសួងផែនការ ដូចមានរាយនាមខាងក្រោម :

១- លោក ខៀវ បូរី ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ

២- លោក ជា ចាន់ឆុំ ជាប្រធាននាយកដ្ឋានផែនការ សង្គមកិច្ច នៃអគ្គនាយកដ្ឋានផែនការ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៤...សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងលិខិត ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

**ប្រការ១.–** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១- សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | សហប្រធាន |
| ២- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |

៤- រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៥- រដ្ឋមន្ត្រី ក្រសួងផែនការ សមាជិក

៦- រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម សមាជិក

៧- រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៨- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា សមាជិក

៩- រដ្ឋមន្ត្រី ក្រសួងបរិស្ថាន សមាជិក

១០- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក

១១- រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ សមាជិក

១២- រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

១៣- រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១៤- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

១៥- រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី សមាជិក

១៦- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៧- រដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៨- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

១៩- ឯកឧត្តមប្រធានក្រុមការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ សមាជិក

**ប្រការ២.–** គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម ÷

- ប្រមែប្រមូលព័ត៌មានទាំងឡាយដែលបំរើឱ្យការរៀបចំសេចក្តីព្រាងច្បាប់

- ប្រមែប្រមូលអនុសាសន៍ពាក់ព័ន្ធ និង ការកែទំរង់អភិបាលកិច្ចនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ពីគ្រប់មជ្ឈដ្ឋាន ទាំងជាតិ អន្តរជាតិ សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍នានា ដើម្បីពិចារណាផ្តួចផ្តើម រៀបចំក្របខ័ណ្ឌគោលនយោបាយ និង ច្បាប់ស្តីពីការគ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ ។

- សិក្សាពិចារណា និង ផ្តល់យោបល់ដល់រាជរដ្ឋាភិបាល អំពីកំណែទំរង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ។

- បង្កើតឱ្យមានវេទិកា ពិគ្រោះយោបល់អំពីក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ទាំងនេះក្នុងចំណោមតួអង្គពាក់ព័ន្ធនានា ។

- ដាក់សេចក្តីព្រាងច្បាប់ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យអនុម័ត ។

- សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីរៀបចំបែបបទដាក់សេចក្តីព្រាងច្បាប់នេះ ជូនរដ្ឋសភា។

**ប្រការ៣.-** ត្រូវបានបង្កើតក្រុមការងារមួយសំរាប់ជាជំនួយការឱ្យគណៈកម្មការអន្តរក្រសួងនេះ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **នង់ ហ៊ុនមារិទ្ធ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **នុត សាអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- **អគ្គនាយក ឬ អគ្គនាយករង** នៃក្រសួងសមាជិកគណៈកម្មការ | | សមាជិក |

គណៈកម្មការអាចចាត់មន្ត្រីពីក្រសួង ស្ថាប័ន ក្នុងគណៈកម្មការឱ្យចូលរួមជាសមាជិកក្រុមការងារបន្ថែមទៀតតាមការចាំបាច់ ។

តួនាទី ភារកិច្ច និង របៀបរបបការងាររបស់ក្រុមការងារខាងលើនេះ ត្រូវកំណត់ដោយសេចក្ដីសំរេចរបស់គណៈកម្មការ ។

**ប្រការ៤.-** ក្រុមការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវភ្ជាប់ការងាររបស់ខ្លួនជាមួយគណៈកម្មការនេះ ដើម្បីរៀបចំសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយជូនរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

**ប្រការ៥.-** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ តំណាងក្រសួងស្ថាប័នផ្សេងទៀតដែលមិនស្ថិតក្នុងសមាជិកគណៈកម្មការ ដើម្បីចូលរួមប្រជុំពិភាក្សា និង សហការបំពេញការងារតាមការជាក់ស្ដែង ។

គណៈកម្មការមានសិទ្ធិចាត់ចែង ប្រើប្រាស់មន្ត្រីរាជការនៃទីស្ដីការក្រសួងមហាផ្ទៃ និង អាចស្នើសុំមន្ត្រីជំនាញពីក្រសួង ស្ថាប័ននានា ដែលជាសមាជិកគណៈកម្មការឱ្យចូលរួមជួយការងារតាមការចាំបាច់ បន្ទាប់ពីមានការឯកភាពពីក្រសួង ស្ថាប័នសាមី នៃមន្ត្រីទាំងនោះ ។

គណៈកម្មការអាចស្នើចាត់បញ្ជូនសមាជិកគណៈកម្មការ ឬសមាជិកក្រុមការងាររបស់ខ្លួន ឱ្យទៅធ្វើទស្សនកិច្ចសិក្សាដកពិសោធន៍នៅបរទេសតាមការចាំបាច់ បន្ទាប់ពីបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ៦.-** សមាជិកទាំងអស់នៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវអញ្ជើញចូលរួមប្រជុំ និងធ្វើការងារតាមសេចក្ដីអញ្ជើញ និង ការណែនាំរបស់សហប្រធាន ។

**ប្រការ៧.-** គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៨.-** ថវិកា សំភារៈ សំរាប់បំពេញការងាររបស់គណៈកម្មការត្រូវប្រើប្រាស់ក្នុងថវិកាផ្នែករដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ ។

គណៈកម្មការអាចស្នើសុំ ឬទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និង សំភារៈ ពីប្រភពក្នុងស្រុក និងអន្តរជាតិ សំរាប់គាំទ្រដល់ការតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ប្រការ៩.-** គណៈកម្មការនេះនឹងត្រូវបញ្ចប់អណត្តិនៅពេលដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ចូលជាធរមាន ។

**ប្រការ១០.-** ក្រសួង ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន ដូចដែលមានចែងក្នុងប្រការ១ និង ប្រការ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចរចាជាមួយភាគីចិនអំពីការទិញនាវាប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធតាមដងសមុទ្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងលើស្មារតីនៃការពិភាក្សារវាងថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជា-មានិតចិន ក្នុងឱកាសសម្តេចនាយករដ្ឋមន្ត្រីអញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន
- យោងស្មារតីនៃកិច្ចពិភាក្សារវាងគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និង Exim Bank

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចរចាជាមួយភាគីចិនអំពីការទិញនាវាប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធតាមដងសមុទ្រ ដូចមានសមាសភាពខាងក្រោម :

១- ឯកឧត្តម **អ៊ឹក រ៉ាម៉ិន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុខ សំខាន់** មេបញ្ជាការកងទ័ពជើងទឹក អនុប្រធាន

៣- ឯកឧត្តម **ជា ច័ន្ទដេត** នាយកខុទ្ទកាល័យ និងទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី សុខ អាន សមាជិក

៤- លោក **ឆោ យុទ្ធថា** ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- ចរចាជាមួយភាគីចិន
- ពិនិត្យការសិក្សាបឋម
- ពិនិត្យកិច្ចព្រមព្រៀងទិញលក់
- ពិនិត្យកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន
- តាមដានការអនុវត្តកិច្ចព្រមព្រៀងទិញ-លក់

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ដូចមាន ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល** :

*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ* ✓

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ០៧ .សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃរាជាយស្វ័យយានកម្ពុជា លើការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : បង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃរាជាយស្វ័យយានកម្ពុជាលើការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ លីមនៅ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុក ចាន់** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម | **សំ សុខផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៥- ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៧- ឯកឧត្តម | **ជា វ៉ាន់ដេត** | នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៨- ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | នាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- ឯកឧត្តម | **សុខុម ភគចន្ទមុនី** | ប្រធានអគ្គនាយករាជាយស្ម័យយានកម្ពុជា | សមាជិក |
| ១០- លោក | **តាំង ឈាងខ័ណ្ឌ** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក | **ហ៊ី អានវ៉ានិថ** | នាយកខុទ្ទកាល័យក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |

**ប្រការ ២**: គណៈកម្មការ មានភារកិច្ចពិនិត្យការសិក្សាបឋម ការងារជំនាញ និងការងារវាយតម្លៃការធ្វើឯកជនភាវូបនីយកម្មលើសេវាដឹកជញ្ជូន ការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ ។

**ប្រការ ៣**: គណៈកម្មការ ត្រូវរាយការណ៍អំពីលទ្ធផលនៃការងាររបស់ខ្លួនជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។

**ប្រការ ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល** :

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៤*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៣៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ ចំពោះប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ដែលសហគ្រាសត្រូវបង់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតំរូវនៃច្បាប់ស្តីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០០៥ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ០៧៤ ប្រ.កសហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ ។
- បានឃើញការចាំបាច់របស់នាយកដ្ឋានពន្ធដារ

## សម្រេច :

**ប្រការ ១.-** ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ។

**ប្រការ ២.-** ១ ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។

២- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធដែលដាក់ជូនរដ្ឋបាលសារពើពន្ធ ។

៣ ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគី ដែលរដ្ឋបាលសារពើពន្ធបានធ្វើ និង បានប្រគល់ឱ្យនោះ ។

**ប្រការ ៣.-** ១ ដូចមានចែងក្នុងមាត្រា ១០៨ នៃច្បាប់ស្តីពីសារពើពន្ធ ដូចមានក្នុងឃ្លាខាងលើ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាស មិនរាយការណ៍ មិនបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

២- រដ្ឋបាលសារពើពន្ធ **មានសិទ្ធិអនុវត្តវិធានការតឹងទារប្រាក់ពន្ធ** ប្រាក់ពន្ធបន្ថែម និងការប្រាក់ដែលសហគ្រាសត្រូវបង់តាមការតំរូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ដូចដែលត្រូវអនុវត្តចំពោះសហគ្រាសដែរ ។

**ប្រការ ៤.-** វិធានការតឹងទាររបស់រដ្ឋបាលសារពើពន្ធ រួមមាន:

១- ការតម្រូវឱ្យបុគ្គលនានា រួមមានរូបវន្តបុគ្គល នីតិបុគ្គល អង្គការ ស្ថាប័នរដ្ឋនានា... ដែលមានកាតព្វកិច្ចត្រូវសងអ្វីមួយ ដូចជាប្រាក់ខ្ចី ប្រាក់ឈ្នួល ប្រាក់ទូទាត់ការទិញទំនិញ ឬសេវា អោយដល់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឱ្យប្រគល់សំណងនោះដល់នាយកដ្ឋានពន្ធដារ ទោះជាសាច់ប្រាក់ ឬជាវត្ថុក្តី ក្នុងចំនួនដែលមានតំលៃមិនលើសពីចំនួនប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និងចំណាយក្នុងការប្រមូលពន្ធ ។

២- ការចេញលិខិតជូនដំណឹងទៅជូនរាជធានីមានសមត្ថកិច្ច ស្នើសុំឱ្យទុកជាមោឃៈ ឬព្យួរទុកនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗ ដែលអនុញ្ញាតឱ្យសហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

សហគ្រាសអនុវត្តសកម្មភាពណាមួយ ជាអាទិ៍មាន សកម្មភាពលទ្ធកម្ម ជួលទ្រព្យសម្បត្តិ គំរោងវិនិយោគ ការចុះបញ្ជីពាណិជ្ជកម្ម... ជាដើម ។

៣ ការបញ្ឈប់ប្រតិបត្តិការនាំចេញ នាំចូល សំដៅដល់ការឃាត់ទុកទំនិញដែលជារបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ទីចាត់ការគយ និងរដ្ឋាករ និងការលក់ទំនិញទាំងនោះ បើសិនជាការចាំបាច់ក្នុងបរិមាណដែល មានតំលៃមិនលើសពីប្រាក់ពន្ធ ប្រាក់បន្ថែម ការប្រាក់ និងចំណាយក្នុងការប្រមូលពន្ធ ។

៤- ការឃាត់ទុកគណនីនៅធនាគាររបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងការតម្រូវឱ្យធនាគារប្រគល់ឱ្យនាយកដ្ឋានពន្ធដារនូវប្រាក់ក្នុងគណនីរបស់សហគ្រាស ឬរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ ទាំងនោះក្នុងចំនួនដែលមិនលើសពីចំនួនទឹកប្រាក់សំរាប់ទូទាត់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និង ចំណាយក្នុងការប្រមូលពន្ធ ។

៥- ការរឹបអូស ការលក់ទ្រព្យសម្បត្តិរបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសក្នុងចំនួនដែលមានតំលៃគ្រប់គ្រាន់សំរាប់ទូទាត់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងចំណាយក្នុងការប្រមូលពន្ធ ទោះបីជាទ្រព្យសម្បត្តិត្រូវបានកាន់កាប់ដោយបុគ្គលខ្លួនឯង ឬដោយតតិយជនក្តី ។

**ប្រការ ៥.-** នីតិវិធី និងបែបបទនៃការអនុវត្តន៍វិធានការតឹងទារ ដូចមានចែងក្នុងប្រការ ៤ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធលេខ ៣៧៤ ប្រ.កសហវ.ពដ ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ១៩៩៨ ។

**ប្រការ ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៥

**គាត ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីមុខការ"
  គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ០១៥ សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥

# សេចក្ដីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទដែលកំពុងធ្វើចរាចរ ប្រើប្រាស់ ឬសន្និធិយានយន្តនៅតាមបណ្ដាអាជីវកម្មដ្ឋាន លំនៅដ្ឋាន ឬកន្លែងផ្សេងទៀត ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលខកខានដោយប្រការណាមួយក្នុងការបំពេញបែបបទបង់ពន្ធ និងអាករនាពេលនាំចូលស្របតាមច្បាប់ជាធរមានកន្លងមកឱ្យបានជ្រាបថា នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុគ្រោះឱ្យមានការចូលមកបំពេញកាតព្វកិច្ចពន្ធដោយស្ម័គ្រចិត្តលើយានយន្តប្រភេទដូចខាងលើនេះក្ដី ដោយមានការពន្យាពេលជាបន្តបន្ទាប់ក្ដី ក៏មានតែម្ចាស់យានយន្តចំនួនជាង ៣.០០០ គ្រឿងប៉ុណ្ណោះ បានអនុវត្តល្អតាមខ្លឹមសារនេះ ។ ដោយឡែកម្ចាស់យានយន្តមួយចំនួនទៀតនៅតែរារែកមិនទាន់ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធនៅឡើយ ហើយម្ចាស់យានយន្តខ្លះបានប្រើប្រាស់ក្លែងបន្លំឯកសារសំគាល់យានយន្តផ្សេងៗដូចជាបានប្រើលតាប័ត្រក្លែងក្លាយ ឬលតាប័ត្រខុសប្រភេទរថយន្ត ក៏ដូចជាផ្លាកលេខមិនស្របច្បាប់ប្រភេទថ្មី ឬប្រភេទចាស់ ដែលនាំឱ្យមានបទល្មើសធ្ងន់ធ្ងរបន្ថែមទៀតពីលើបទល្មើសគេចពន្ធដែលមានស្រាប់។

ចំពោះមុខបាតុភាពអសកម្មទាំងនេះនិងដើម្បីជៀសវាងនូវផលវិបាកជាយថាហេតុនានា ជាពិសេសក្នុងពេលដែលអាជ្ញាធរមានសមត្ថកិច្ចចុះបង្ក្រាប ឬចាប់ឃាត់នោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឱ្យម្ចាស់យានយន្តគ្រប់ប្រភេទដូចរៀបរាប់ខាងលើ ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធឱ្យបានរួសរាន់នៅការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ ឬនៅតាមសាខាគយនិងរដ្ឋាករខេត្ត ក្រុង ទាំងអស់ដោយពុំរង់ចាំការផាកពិន័យអ្វីឡើយ ។ សមត្ថកិច្ចគយនិងរដ្ឋាករ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុលោមតាមការសំរេចរបស់រាជរដ្ឋាភិបាល ដើម្បីដំណើរការបង្ក្រាបបទល្មើសទាំងនេះនៅតាមដងផ្លូវសាធារណៈ កន្លែងសន្និធិ និងនៅតាមលំនៅដ្ឋាន ក៏ដូចជាអាជីវកម្មដ្ឋាននានាជាបណ្ដើរៗយ៉ាងម៉ឺងម៉ាត់ ដោយត្រូវចាប់ឃាត់ជាបណ្ដោះអាសន្ននូវយានយន្តល្មើសច្បាប់ទាំងនេះ បង្ខំឱ្យបង់ពន្ធ អាករ និងពិន័យតាមច្បាប់ជាធរមាន ដោយគ្មានការយោគយល់អ្វីឡើយ ហើយក្នុងករណីចាំបាច់បញ្ជូនករណីទាំងនេះទៅតុលាការមានសមត្ថកិច្ចដើម្បីផ្ដន្ទាទោសតាមច្បាប់ ។

អាស្រ័យហេតុនេះសូមឱ្យម្ចាស់យានយន្តដូចរៀបរាប់ខាងលើ ចូលខ្លួនដោយស្ម័គ្រចិត្តមកអនុវត្តតាមខ្លឹមសារសេចក្ដីជូនដំណឹងនេះប្រកបដោយក្ដីយោគយល់គ្នាទៅវិញទៅមក ដោយចាត់ទុកទង្វើនេះជាការចូលរួមដោយផ្ទាល់ក្នុងការកសាងសង្គមនីតិរដ្ឋនៅកម្ពុជា។ សូមម្ចាស់យានយន្តដូចរៀបរាប់ខាងលើមកទំនាក់ទំនងនៅទីចាត់ការគយនិងរដ្ឋាករ (ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ ឬតាមទូរស័ព្ទលេខ ០១២ ៨២៨៧៧៧ - ០១២ ២៧៩៨៩៩ និងលេខ ០១២ ៤៧៨៩៩៩ រាល់ពេលម៉ោងធ្វើការ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រធានគណៈកម្មការអន្តរក្រសួងទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ

គាត ឈន់

ចំលងជូន
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងការពារជាតិ
- -អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- -គ្រប់សាលាខេត្ត-ក្រុង (ដើម្បីជូនជ្រាបជាព័ត៌មាន)
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

លេខ ០១៧ សហវ.អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងចំពោះ អ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ទាំងឡាយអោយបានជ្រាបថា : យោងតាមមាត្រា ៩២.៧ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិអនុវត្តវិធានការតឹងទារប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលសហគ្រាសមិនបានបង់ ។ ម្យ៉ាងទៀត មាត្រា ១០៨ នៃច្បាប់ស្តីពីសារពើពន្ធបានចែងថា "ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើអោយសហគ្រាសមិនរាយការណ៍ មិនបង់ប្រាក់ពន្ធ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ឬមិនអោយបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលត្រូវបង់" ។

កន្លងមក មានសហគ្រាសមួយចំនួន ទោះបីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការអំពាវនាវអោយមកទូទាត់បំណុលពន្ធតាមវិធានការទន់ភ្លន់ក៏ដោយ ក៏សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ទាំងនោះនៅព្រងើយកន្តើយមិនព្រមមកបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ដែលសហគ្រាសជំពាក់នៅឡើយ ។ ជាថ្មីម្តងទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមអញ្ជើញអ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬជាបណ្ណាធិការ ឬជាកម្មសិទ្ធិករសហគ្រាស រួសរាន់មកធ្វើការទូទាត់បំណុលពន្ធអោយបានគ្រប់ចំនួន គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងធ្វើការទាក់ទង និងបន្តទំនាក់ទំនងជាទៀងរហូតជាមួយស្ថាប័ន អង្គភាពនានា បន្តដាក់បទបញ្ជាអោយនាយកដ្ឋានទាំងឡាយដែលចំណុះខ្លួន ដើម្បីយកវិធានការតឹងទារចំពោះក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ដែលមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ទោះជាអភិបាលនោះ ឬបណ្ណាធិការនោះ ឬកម្មសិទ្ធិករនោះ ទទួលខុសត្រូវ ឬគ្រប់គ្រងក្រុមហ៊ុនណាមួយទៀត ដែលមិនមានការជំពាក់ក៏ដោយ ។ វិធានការតឹងទារមានដូចខាងក្រោម :

១- កាត់យកប្រាក់ក្នុងចំនួនដែលមិនលើសពីបំណុលពន្ធមុនពេលបើកទូទាត់ប្រាក់ខ្ចី ប្រាក់ឈ្នួល ប្រាក់ថ្លៃទិញទំនិញ ឬសេវាដែលស្ថាប័នរដ្ឋ ឬអង្គភាពរដ្ឋនានា ត្រូវសងអោយក្រុមហ៊ុន ឬត្រូវសងអោយអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាស ដែលមានជំពាក់បំណុលពន្ធ ។

២- មិនអនុញ្ញាតអោយក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាសដែលជំពាក់បំណុលពន្ធ ចូលរួមក្នុងការដេញថ្លៃផ្គត់ផ្គង់ទំនិញ ឬសេវានានា ឬចុះបញ្ជីធ្វើសកម្មភាពណាមួយ ដូចជាបង្កើតក្រុមហ៊ុនថ្មី ឬសកម្មភាពវិនិយោគ ជួលទ្រព្យសម្បត្តិរដ្ឋ... ជាដើម ។

៣- ទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗ ដែលអនុញ្ញាតអោយក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនៃសហគ្រាសជំពាក់បំណុលពន្ធរដ្ឋ អនុវត្តសកម្មភាពណាមួយ ។

៤- ឃាត់ទុកគណនីធនាគារ

៥- រឹបអូសទ្រព្យសម្បត្តិក្នុងចំនួនមួយមិនលើសពីបំណុលពន្ធ និងចំណាយក្នុងការប្រមូលពន្ធ ក្នុងនោះរួមមានទាំងការហាមឃាត់ការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិទ្រព្យសម្បត្តិរបស់អ្នកជំពាក់ពន្ធផង ។

ដូចនេះ ដើម្បីជៀសវាងនូវផលវិបាកដែលកើតឡើងជាយថាហេតុចំពោះក្រុមហ៊ុន ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស នៅពេលមានការអនុវត្តន៍វិធានការតឹងទារនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថា អ្នកឧកញ៉ា លោក លោកស្រី ជាអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស មុខជានឹងស្ម័គ្រចិត្តអញ្ជើញមកទូទាត់បំណុលពន្ធភ្លាម ។ ក្នុងករណីចង់ដឹងអំពីព័ត៌មានផ្សេងៗទាក់ទងនឹងបំណុលពន្ធ ឬវិធានការលំអិតដែលនឹងត្រូវអនុវត្តសំរាប់វិធានការតឹងទារបំណុលពន្ធនេះ សូមទាក់ទងទូរស័ព្ទលេខ ០១២ ៦២១ ៦២៩, ០១២ ៨៣៥ ៩៦៣ និង ០១២ ៤៩៤ ៩៥៩ ឬទំនាក់ទំនងផ្ទាល់ជាមួយផ្នែកសេវាអ្នកជាប់ពន្ធនៃការិយាល័យប្រមូលពន្ធតាមរបបពិត និងការិយាល័យតឹងទារបំណុលពន្ធ នៃនាយកដ្ឋានពន្ធដារគ្រប់ម៉ោងធ្វើការ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

1

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ០៧០ MOC / M 2005

# ប្រកាស

## ស្តីពីការកែសំរួលនីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម .
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ៣៦០ MoC/M1999 ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ១៩៩៩ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការបង្កើតគណកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌដែលជាកម្មវត្ថុ នៃការកំណត់បរិមាណដោយសហរដ្ឋអាមេរិក
- បានឃើញប្រកាសលេខ ១៩៩ MoC/M2004 ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៤ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ C/O (Certificate of Origin). វិក័យប័ត្រពាណិជ្ជកម្ម C/I (Commercial Invoice). អាជ្ញាប័ណ្ណនាំចេញ E/L (Export License) ចំពោះមុខទំនិញដែលត្រូវនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក
- បានឃើញការចាំបាច់នៃការងារនាំចេញផលិតផលកម្ពុជាក្នុងដំណាក់កាលថ្មី

## សម្រេច

**ប្រការ ១ :** ត្រូវបានកែសម្រួលនិងបំពេញបន្ថែមប្រការ ១ ចំណុច ក-១ នៃប្រកាសលេខ ២៦១ MoC/ M2005 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ ដោយអនុវត្តការបង់***កម្រៃគ្រប់គ្រងការនាំចេញ*** ( Export Management Fee - EMF ) ទៅតាមតំលៃកែសម្រួលថ្មីដូចមានចែងក្នុងតារាងខាងនេះ :

| Category | EMF Revised | KHR/Unit |
|---|---|---|
| **331/631** | 100 | KHR/DPR |
| **334/634** | 1,000 | KHR/DOZ |
| **335/635** | 1,000 | KHR/DOZ |
| **338/339** | 2,500 | KHR/DOZ |
| **340/640** | 2,500 | KHR/DOZ |
| **345** | 3,000 | KHR/DOZ |
| **347/348/ 647/648** | 3,000 | KHR/DOZ |
| **352/652** | 100 | KHR/DOZ |
| **435** | 3,000 | KHR/DOZ |
| **438** | 3,000 | KHR/DOZ |
| **445/446** | 3,000 | KHR/DOZ |
| **638/639** | 2,500 | KHR/DOZ |
| **645/646** | 3,500 | KHR/DOZ |
| ***218*** | 100 | KHR/1,000m2 |
| ***220*** | 100 | KHR/1,000m2 |
| **237** | 100 | KHR/DOZ |
| **239** | 100 | KHR/DOZ |
| ***313*** | 100 | KHR/1,000m2 |
| ***326*** | 100 | KHR/1,000m2 |
| **333** | 500 | KHR/DOZ |
| **336** | 1,000 | KHR/DOZ |
| **337** | 1,000 | KHR/DOZ |
| **341** | 1,000 | KHR/DOZ |
| **342** | 1,000 | KHR/DOZ |
| **346** | 1,000 | KHR/DOZ |
| **349** | 500 | KHR/DOZ |
| **350** | 500 | KHR/DOZ |
| **351** | 500 | KHR/DOZ |
| **354** | 5,000 | KHR/DOZ |
| **359** | 500 | KHR/DOZ |
| **360** | 100 | KHR/DOZ |
| **361** | 500 | KHR/DOZ |
| **362** | 500 | KHR/DOZ |
| **363** | 100 | KHR/DOZ |
| **367** | 100 | KHR/DOZ |
| **369** | 100 | KHR/DOZ |

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708

| | | |
|---|---|---|
| **433** | 5,000 | KHR/DOZ |
| **434** | 8,000 | KHR/DOZ |
| **436** | 1,000 | KHR/DOZ |
| **439** | 1,000 | KHR/DOZ |
| **440** | 1,000 | KHR/DOZ |
| **442** | 5,000 | KHR/DOZ |
| **443** | 4,000 | KHR/DOZ |
| **444** | 2,000 | KHR/DOZ |
| **447** | 4,000 | KHR/DOZ |
| **448** | 5,000 | KHR/DOZ |
| **459** | 100 | KHR/DOZ |
| **611** | 100 | KHR/DOZ |
| ***613*** | 100 | KHR/1,000m2 |
| ***617*** | 100 | KHR/1,000m2 |
| ***619*** | 100 | KHR/1,000m2 |
| ***620*** | 100 | KHR/1,000m2 |
| ***625*** | 100 | KHR/1,000m2 |
| ***627*** | 100 | KHR/1,000m2 |
| ***628*** | 100 | KHR/1,000m2 |
| ***629*** | 100 | KHR/1,000m2 |
| ***633*** | 1,000 | KHR/1,000m2 |
| **636** | 500 | KHR/DOZ |
| **641** | 500 | KHR/DOZ |
| **642** | 500 | KHR/DOZ |
| **643** | 800 | KHR/DOZ |
| **644** | 800 | KHR/DOZ |
| **649** | 500 | KHR/DOZ |
| **650** | 500 | KHR/DOZ |
| **651** | 100 | KHR/DOZ |
| **653** | 4,000 | KHR/DOZ |
| **654** | 5,000 | KHR/DOZ |
| **655** | 2,000 | KHR/DOZ |
| **659** | 500 | KHR/DOZ |
| **666** | 100 | KHR/DOZ |
| **669** | 100 | KHR/DOZ |
| **670** | 100 | KHR/DOZ |
| **736** | 100 | KHR/DOZ |
| **834** | 3,000 | KHR/DOZ |
| **835** | 3,000 | KHR/DOZ |
| **836** | 3,000 | KHR/DOZ |
| **838** | 3,000 | KHR/DOZ |
| **839** | 500 | KHR/DOZ |
| **840** | 4,000 | KHR/DOZ |
| **842** | 500 | KHR/DOZ |
| **844** | 500 | KHR/DOZ |
| **845** | 500 | KHR/DOZ |
| **846** | 500 | KHR/DOZ |
| **847** | 600 | KHR/DOZ |
| **848** | 600 | KHR/DOZ |
| **851** | 600 | KHR/DOZ |

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708

| | | |
|---|---|---|
| **852** | 800 | KHR/DOZ |
| **859** | 500 | KHR/DOZ |
| **870** | 500 | KHR/DOZ |
| **899** | 500 | KHR/DOZ |

**ប្រការ ២ :** ខ្លឹមសារដទៃទៀតនៃសេចក្តីប្រកាសលេខ ២៦១ MoC M2005 ដូចមានចែងខាងលើក្នុងប្រការ ១ នៅមានតំលៃជាធរមានដដែល ។

**ប្រការ ៣ :** អគ្គាធិការ, អគ្គនាយកបច្ចេកទេស, អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ, ប្រធាននាយកដ្ឋានរដ្ឋបាល, ប្រធាននាយកដ្ឋានគណនេយ្យ, ប្រធាននាយកដ្ឋានកាំកុងត្រូល, នាយិកាខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស

-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី

-ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា

-អគ្គប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក

-ទីចាត់ការគយ និង រដ្ឋាករ

-សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ